ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

សំណុំរឿងព្រហ្មទណ្ឌ

លេខ:២១៥

ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២

សាលដីកា

លេខ:១៦២

ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០-០៦-២០១៣ ដែលមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោមៈ

១-ឯកឧត្តម.... ជាប្រធាន

២-លោកស្រី....ចៅក្រម

៣-លោក .... ចៅក្រម

៤-លោក..... ចៅក្រម

៥-លោក..... ចៅក្រម

**ក្រឡាបញ្ជី**

លោក .............

**តំណាងមហាអយ្យការ**

-លោក ................ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ៨៣(ក្រVបស) ចុះថ្ងៃទី១៧-៦-២០១២ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ២១៥ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ របស់តុលាការកំពូល។

**ពីបទ** មនុស្សឃាតគិតទុកជាមុនប្រព្រឹត្តនៅភូមិសាលាគំរូសង្កាត់ព្រៃញីក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១១ខែមិថុនាឆ្នាំ២០០៩បទល្មើស

ព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

**-ជនជាប់ចោទ**

១-ឈ្មោះ...ម្ចាស់បណ្តឹងសាទុក្ខ ភេទប្រុស អាយុ២៦ ឆ្នាំជាតិខ្មែរ មានមុខរបររកស៊ីលក់ដូរ កើតនៅភូមិចុងខ្លុង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ មានទីលំនៅសព្វថ្ងៃនៅភូមិចុងខ្លុង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ មានឪពុកឈ្មោះ.....(ស) ម្តាយឈ្មោះ.......(រ) ប្រពន្ធឈ្មោះ......មានកូន០១នាក់ ទោសពីមុនគ្មាន។

២-ឈ្មោះ..........ជាម្ចាស់បណ្តឹងសាទុក្ខ ភេទប្រុស អាយុ៤៤ ឆ្នាំ ជាតិខ្មែរឥស្លាម កើតនៅភូមិត្រពាំងខ្លុង ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ចាម មានមុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្ននៅភូមិចុងខ្លុយ ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ឪពុកឈ្មោះ.....ម្តាយឈ្មោះ......ប្រពន្ធឈ្មោះ........មានកូន០៧នាក់ ទោសពីមុនគ្មាន។

-ជនជាប់ចោទទាំងពីរមានលោក...ជាមេធាវីការពារសិទ្ធិជនជាប់ចោទ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ....ជាចុងបណ្តឹងសាទុក្ខ ភេទស្រីអាយុ៥០ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅភូមិក្រាំងតាសែន សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ជនរងគ្រោះឈ្មោះ........ភេទប្រុស បានធ្វើដំណើរមកពីលេងផ្ទះកូននៅភូមិចុងខ្លុងឃុំអូរសណ្តាន់ស្រុកក្រគរ ខេត្តពោធិ៍សាត់ ដោយជិះម៉ូតូលើកំណាត់ផ្លូវជាតិលេខ៥ ឆ្ពោះមកទីរួមខេត្តពោធិ៍សាត់។ លុះមកដល់ភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ នៅវេលាម៉ោង១១ និង៣០នាទី មានជនល្មើសចំនួន០២នាក់ ជិះម៉ូ

តូឌុបគ្នាមកតាមក្រោយ មកដល់កៀក បានបាញ់ជនរងគ្រោះនឹងកាំភ្លើងខ្លីចំនួនមួយគ្រាប់ ត្រូវក្រោមឆ្អឹងជំនីខាងឆ្វេងបណ្ដាលឱ្យរបួសធ្ងន់ និងបណ្ដាលឱ្យស្លាប់ក្រោយពីបានសង្គ្រោះនៅមន្ទីរពេទ្យ។

-បានឃើញសេចក្ដីសន្និដ្ឋាន របស់តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ថាៈ

-ចោទប្រកាន់លើជនជាប់ចោទឈ្មោះ......និងឈ្មោះ.......ពីបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោស តាមមាត្រា៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ០៤(ផ)ចុះថ្ងៃទី០៩ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តពោធិ៍សាត់ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ឱ្យឈ្មោះ.............រួចខ្លួនពីបទចោទពីបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោស តាមមាត្រា៣នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២-លើកចោលការប្ដឹងទាមទារជំងឺចិត្ត របស់អ្នកតំណាងដោយអាណត្តិដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ..........ចំនួន ១០០០០(ដប់ពាន់ដុល្លាអាមេរិក)ពីជនជាប់ចោទឈ្មោះ.......ដោយខុសទៅនឹងគតិច្បាប់។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៩ខែកុម្ភៈ ឆ្នាំ២០១០ចំពោះមុខជនជាប់ចោទនិងអ្នកតំណាងដោយអាណត្តិដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាស

ជាសាធារណៈនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១០ កំបាំងមុខជនជាប់ចោទ និងអ្នកតំណាងដោយអាណត្តិដើមបណ្តឹងរដ្ឋប្បវេណី។ បើកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖ ពុំមានភស្តុតាងដោះបន្ទុកធន់ល្មម អាចឱ្យជនត្រូវចោទរួចផុតពីបទចោទឡើយ។គប្បីបដិសេធសាលក្រមលេខ០៤(ផ)ចុះថ្ងៃទី០៩ខែកុម្ភៈឆ្នាំ២០១០ ចោលជាអសារបង់ ដោយចោទប្រកាន់ជនត្រូវចោទ ដូចការចោទប្រកាន់របស់តំណាងអយ្យការ។

-បានឃើញសាលដីកាបៀបលេខ០៣ក្រVបស ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច៖

១-ស៊ើបសួរបន្ថែមនូវ

-ពេលវេលាដែលជនរងគ្រោះត្រូវគេបាញ់សម្លាប់

-ពេលវេលាផ្សេងៗទៀតរបស់ជនជាប់ចោទ និងសាក្សី ដែលបានឃើញហេតុការណ៍និងសាក្សីដែលនៅជាមួយជនជាប់ចោទ។

-សាកសួរលើឈ្មោះ.......និងឈ្មោះ......ជានគរបាល នៃអធិការដ្ឋានក្រុងពោធិ៍សាត់ ពីពេលវេលាដែលអ្នកទាំងពីរបានកសាងក្នុងកំណត់ហេតុ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៨៣ក្រVបស ចុះថ្ងៃទី១៧ខែកក្កដាឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច៖

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ របស់ឈ្មោះ.... ជាតំណាងអយ្យការអមសាលាដំបូង ខេត្តពោធិ៍សាត់ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ០៤ (ផ) ចុះថ្ងៃទី០៩-០២-២០១០ របស់សាលាដំបូងខេត្តពោធិ៍សាត់ចោល។

៣-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ.....ភេទប្រុសអាយុ២៦ឆ្នាំ និងជនជាប់ចោទឈ្មោះ.....ភេទប្រុសអាយុ៤៤ ឆ្នាំ ដាក់ពន្ធនាគារម្នាក់ៗកំណត់១៧ ឆ្នាំ ពីបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១១-៦-២០០៩ តាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ៣៩០ ចំណុច១,២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ..........សងសំណងជំងឺចិត្តចំនួន២០,០០០,០០០រៀល(ម្ភៃលានរៀល)ទៅដើមបណ្តឹងឈ្មោះ......ការទាមទារលើសពីនេះបដិសេធចោល។

-បង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ...យកអនុវត្តទោសនៅពន្ធនាគារខេត្តពោធិ៍សាត់ តាមអំណាចសាលដីកានេះ តាមមាត្រា៤០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី២០-៦-២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៧-៧-២០១២ ដោយ សម្រេចសេចក្តី៖

-កំបាំងមុខដើមបណ្តឹង ចំពោះមុខមេធាវី

-បើកសិទ្ធិប្តឹងតវ៉ា តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ២០៥,២០៦ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១២ របស់ឈ្មោះ.......ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៨៣ (ក្រVបស) ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណាការពារ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២របស់លោក......មេធាវីការពារជនជាប់ចោទទាំងពីរនាក់។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការតុលាការកំពូលថា៖

-ទទួលបណ្តឹងសាទុក្ខលេខ២០៥ និង២០៦ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១២ របស់ឈ្មោះ...ពិតជាត្រឹមត្រូវតាមទម្រង់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៨៣(ក្រVបស) ចុះថ្ងៃទី១៧ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ទុកជា បានការដដែល។

សូមក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

-បានស្តាប់ប្រធានសួរសាវតាជាតិ និង ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ.....នាពេលសវនាការថា៖ មុនពេលចាប់ខ្លួន ខ្ញុំៗនៅផ្ទះ លក់ចានឆ្នាំង ខ្ញុំមិនសុខចិត្តសាលដីកាសាលាឧទ្ធរណ៍ចោទប្រកាន់ខ្ញុំ ព្រោះខ្ញុំមិនបានប្រព្រឹត្តទេ នៅថ្ងៃកើតហេតុ ពេលព្រឹកខ្ញុំទៅលក់ពីព្រឹកដល់យប់ទើបមកផ្ទះវិញ ពេលខ្ញុំភ្ញាក់ព្រើតដោយមិនបានដឹងអ្វីទាំងអស់។ជនរងគ្រោះ ស្គាល់គឺព្រោះគាត់ជាអ្នកស្រុកខ្ញុំៗពុំដែលមានទំនាស់ជាមួយគ្នាទេ នៅក្នុងភូមិខ្ញុំមានឈ្មោះ.......ច្រើនហើយឈ្មោះ..ខ្ញុំក៏ច្រើនដែរ ដូច្នេះការដែលគេចោទប្រកាន់មកលើរូបខ្ញុំគឺជាការភាន់ច្រឡំ។

-សំណូមពរ ជួយដោះលែងខ្ញុំផង ព្រោះខ្ញុំមិនបានប្រព្រឹត្តទេ។

-បានស្តាប់ប្រធានសួរសាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ....នាពេលសវនាការថា៖សព្វថ្ងៃខ្ញុំ នៅផ្ទះធ្វើស្រែ ខ្ញុំជាមនុស្ស

ស្អាតស្អំ បែរជាគេចោទខ្ញុំថាសម្លាប់មនុស្សទៅវិញក្នុងរឿងនេះខ្ញុំមិនបានប្រព្រឹត្តទេ។ ម៉ោង១១ ថ្ងៃត្រង់ខ្ញុំទៅផឹកកាហ្វេ គឺជួបមេប៉ុស្តិ៍ មេកងឈ្មោះ....ពេលនោះខ្ញុំយកឱសទៅធ្វើ អត់ជួបអ្នកធ្វើក៏ផឹកកាហ្វេខ្ញុំគ្មានទំនាស់អ្វីជាមួយជនរងគ្រោះទេ ផ្ទះខ្ញុំនៅឆ្ងាយពីផ្ទះឈ្មោះ.....ប្រហែល៤០០ម ហើយពីផ្ទះខ្ញុំទៅកន្លែងកើតហេតុជិះម៉ូតូប្រហែល ១ម៉ោង គេប្រាប់ខ្ញុំថាឈ្មោះ.......ត្រូវគេសម្លាប់ពេលនោះប្រហែលម៉ោង៤ទៅ៥ ខ្ញុំនៅផ្ទះចងគោ។

សំណូមពរ រកយុត្តិធម៌ឱ្យខ្ញុំព្រោះគេចោទខ្ញុំដោយបំពាន។

-បានស្តាប់ប្រធានសួរសាវតាជាតិ និងចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ.........ពេលសវនាការថា៖

ប្តីខ្ញុំគាត់មានជំងឺជាប់ខ្លួន ប្តីខ្ញុំមិនមានទំនាស់គ្នាជាមួយនរណាទេបើសិនជាមិនមែន០២នាក់ នឹងទេ គាត់មិនឆ្លើយដាក់ទេ ប្តីខ្ញុំគាត់ជាគ្រូបុរាណ គ្មានជម្លោះជាមួយពីណាទេ ពេលគាត់ត្រូវរបួសពេលនោះខាងស្រុកសំពៅមាសសួរថា អ្នកណាបាញ់ គាត់ថាឈ្មោះ........ទាំងឈ្មោះប្រពន្ធទៀត។

-សំណូមពរ សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ ព្រោះក្នុងចិត្តនាងខ្ញុំគិតថា០២នាក់នឹងជាអ្នកបាញ់ប្តីខ្ញុំ។

-បានស្តាប់សេចក្តីសន្និដ្ឋាន របស់លោកមេធាវីឈ្មោះ.....ជាអ្នកការពារជនជាប់ចោទឈ្មោះ.....នាពេលសវនាការថា ឆ្លងតាមការសួរដេញដោល ខ្ញុំបាទសូមសន្និដ្ឋានអំពីអង្គហេតុ ខ្ញុំទទួលស្គាល់ថាជនរងគ្រោះឆ្លើយដាក់កូនក្តីខ្ញុំបាទ ប៉ុន្តែសម្រាប់កូនក្តីខ្ញុំវិញ ជាភាពអយុត្តិធម៌បំផុតសម្រាប់កូនក្តីរបស់ខ្ញុំ ក្នុងការកសាងសំណុំរឿងដោយប៉ូលីស មានភាពស្រពេចស្រពិល ពុំបានរកឃើញភស្តុតាងទាក់ទាញពាក់ព័ន្ធនឹងបទល្មើសនោះទេ នៅថ្ងៃកើតហេតុឈ្មោះ....ឆ្លើយថាតាំងពីប្រហ៊ាម ខ្លួនជូនប្រពន្ធទៅលក់ចានឆ្នាំង លុះដល់ម៉ោង១០ត្រឡប់មកដល់

ផ្ទះវិញបោកខោអាវងូតទឹកហូបបាយ បន្ទាប់មកចូលថ្វាយបង្គំព្រះក្នុងព្រះវិហារ ដោយមានសាក្សីដឹងឮច្រើននាក់។

ចំណែកឯឈ្មោះ........នៅថ្ងៃកើតហេតុខ្លួនយកឱស ទៅធ្វើពីម៉ោង១១ ទៅម៉ោង១២ ថ្ងៃត្រង់គាត់ទៅផឹកកាហ្វេ ក្នុងទៀមកាហ្វេក្បែរសាលាឃុំអូរស ណ្ដាន់ ដោយមានសាក្សីច្រើននាក់ ពិសេសមេឃុំ មេប៉ុស្ដិ៍ ទៅដល់ផ្ទះវិញរៀបចំខ្លួនចូលព្រះវិហារ។

-សំណូមពរ សូមច្រានចោលសាលដីកាព្រហ្មទណ្ឌលេខ៤១៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ទុកជាមិនបានការ។

-បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់លោកមេធាវី...ការពារឱ្យដើមបណ្ដឹងរដ្ឋប្បវេណី នាពេលសវនាការថា៖ខ្ញុំបាទសូមទទួលស្គាល់ថាឈ្មោះ....ច្រើន ប៉ុន្តែកូនក្ដីខ្ញុំបាទឆ្លើយថាអ្នក ដែលបាញ់សម្លាប់គេគឺឈ្មោះ....ព្រមទាំងបញ្ជាក់ពីឈ្មោះប្រពន្ធ គេទៀតដោយប្រពន្ធចុងកូនក្ដីខ្ញុំបាទជាអ្នកស្ដាប់ផ្ទាល់ឮថាឈ្មោះអ្នកទាំងពីរនេះ ជាអ្នកសម្លាប់។ចំពោះសាលាឧទ្ធរណ៍ដាក់ពន្ធនាគារកំណត់១៧ ឆ្នាំ ហេតុអ្វីដាក់តែឈ្មោះ.....ម្នាក់មិនដាក់ឈ្មោះ.....ផងដោយសាសនាអ៊ីស្លាម ឪពុករបស់ឈ្មោះ គាត់ជាគ្រូសង្ឃៀចប្រចាំភូមិ ព្រោះសាសនាអ៊ីស្លាមធំជាងច្បាប់ទៅទៀត ដោយប្រជាជនគាំទ្រគាត់ ទើបគ្មាននរណាចេញមុខចាប់គាត់បាន។

សំណូមពរ មេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីនៃគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២០៥,២០៦ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១២ របស់ជនជាប់ចោទ ធ្វើឡើង ក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនិងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថាការដែលសាលាឧទ្ធរណ៍សម្រេចផ្តន្ទាទោសឈ្មោះ.....ពីបទៈ មនុស្សឃាតគិតទុកជាមុនដោយផ្អែក តែលើភស្តុតាង ដែលបានទទួលពីជនរងគ្រោះតែមួយមុខនោះ តុលាការកំពូលពិនិត្យឃើញថា មិនទាន់គ្រប់គ្រាន់នៅឡើយ ពីព្រោះ៖

-តាមចម្លើយសាក្សីឈ្មោះ...ជាប្រជាជននៅភូមិសាលាគំរូថា នៅពេលកើតហេតុខ្លួនឮសូរផ្ទុះស្មានថាបែកកង់ បន្ទាប់មកឃើញជនរងគ្រោះបណ្តើរម៉ូតូ មកដាក់មុខផ្ទះខ្លួន ហើយប្រាប់ខ្លួនថាម៉ូតូបែកកង់ខ្វាត ត្រូវរូបខ្លួនបណ្តាលឱ្យរបួស។

-តាមចម្លើយរបស់ឈ្មោះ....ថានៅពេលកើតហេតុ ខ្លួនឃើញម៉ូតូជនរងគ្រោះជិះមុនរួចមានម៉ូតូ០១គ្រឿងទៀត ផ្ទុក មនុស្ស០២នាក់ ជិះតាមពីក្រោយ ម្នាក់ពាក់សុវត្ថិភាព ម្នាក់ទៀតពាក់មួកក្រណាត់ លុះម៉ូតូចូលទៅកៀកគ្នាប្រហែល៣ម អ្នកជិះខាងក្រោយ បានទាញកាំភ្លើងខ្លីចេញពីអាវបាញ់ជនរងគ្រោះ រួចជិះម៉ូតូទៅទិសខាងលិច។

-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ...ថាពេលចេញម៉ូតូមក បានឃើញឈ្មោះ.....ម្នាក់ទៀតឈ្មោះ.....ជិះម៉ូតូតាម ពីក្រោយខ្លួន មកដល់ជិតសាលាគំរូ បានបាញ់រូបខ្លួនត្រូវក្រោមឆ្អឹងជំនីរខាងឆ្វេងមួយគ្រាប់។

ដូច្នេះឃើញថា ចម្លើយរបស់ឈ្មោះ....ស៊ីសង្វាក់គ្នានឹងចម្លើយជនរងគ្រោះ ប៉ុន្តែហេតុអ្វីបានជនរងគ្រោះប្រាប់ឈ្មោះ.....បែកកង់ខ្នាតមកត្រូវរូបខ្លួនបណ្តាលឱ្យរបួសទៅវិញ ព្រោះឈ្មោះ.......ជាមនុស្សទីមួយ ដែលជនរងគ្រោះបានប្រាប់ពីហេតុការនេះ ឬមួយក៏ក្រោយពេលរបួសជនរងគ្រោះ មិនដឹងថាត្រូវគេបាញ់ ហើយស្មានថាកង់បែកខ្នាតថ្មមកត្រូវ បណ្តាលឱ្យរបួសទៅវិញ។ រីឯភិនភាគរបស់អ្នកទាំងពីរជាជនសង្ស័យ ក៏មិនបានដឹងដែរ។

-យល់ឃើញថា អាវុធគឺកាំភ្លើង ដែលត្រូវបានប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើសនេះ ក៏មិនទាន់បានស្រាវជ្រាវរកនៅឡើយ ដូច្នេះគប្បីសាលាឧទ្ធរណ៍ធ្វើការស៊ើបអង្កេតបន្ថែម។

-យល់ឃើញថា នៅអយ្យការ អ្នកស្រី......ជាប្រពន្ធរបស់ឈ្មោះ.......ជនរងគ្រោះបានទាមទារសំណងនិងជំងឺចិត្តជា ប្រាក់ចំនួន១០,០០០ដុល្លា ដែលចំណុចនេះសាលាឧទ្ធរណ៍មិនទាន់បានពិចារណាទេ ផ្ទុយទៅវិញសាលាឧទ្ធរណ៍បែរជា ទទួលស្គាល់អ្នក.......ម្នាក់ជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសម្រេចឱ្យសំណងជំងឺចិត្ត២០,០០០,០០០រៀល ទៅវិញ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៨៣(ក្រVបស) ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ មិនត្រឹមត្រូវតាមគិតច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ២០៥ និង២០៦ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ ២០១២ របស់ជនជាប់ចោទ។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ៨៣(ក្រVបស) ចុះថ្ងៃទី១៧ ខែកក្កដាឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ទាំងមូល។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ២១៥ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ ២០១២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីចាត់ការតាមច្បាប់។

៤-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៣ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣។